**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៧០២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគទីតាំងសាលាស្រុកកំពង់ត្របែក ទីតាំងដីមួយផ្នែករបស់ស្នងការដ្ឋាននគរបាលខេត្តកំពត និង ទីតាំងការិយាល័យចរាចរជើងគោករបស់ស្នងការដ្ឋាននគរបាលខេត្តកំពង់ស្ពឺ

**រាជរដ្ឋាភិបាលកម្ពុជា**

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ស្តីពីការប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានឃើញព្រះរាជក្រឹត្យលេខ នស /រកត/០៨០៦/៣៣៧ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និង បញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និង នីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

-របាយការណ៍ស្តីពីការអង្កេតជាសាធារណៈលើទីតាំងសាលាស្រុកកំពង់ត្របែក លេខ៤៦៨ សរសណ ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០០៧ របស់ក្រសួងមហាផ្ទៃ

-របាយការណ៍ស្តីពីការអង្កេតជាសាធារណៈលើទីតាំងការិយាល័យចរាចរជើងគោក នៃស្នងការដ្ឋាននគរបាលខេត្តកំពង់ស្ពឺ លេខ៤៦៩ សរសណ ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០០៧ របស់ក្រសួងមហាផ្ទៃ

-របាយការណ៍ស្តីពីការអង្កេតជាសាធារណៈ លើទីតាំងដីមួយផ្នែកនៃស្នងការដ្ឋាននគរបាល ខេត្តកំពត លេខ ១៤៥៤ លស ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០០៧ របស់ក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.-**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវទីតាំងសាលាស្រុកកំពង់ត្របែក ដែលមានទំហំដី៥.២៨៩ម៉ែត្រក្រឡា ទីតាំងការិយាល័យចរាចរជើងគោកនៃស្នងការដ្ឋាននគរបាលខេត្តកំពង់ស្ពឺទំហំដី១.៣២៤.៣០ម៉ែត្រក្រឡា និង ទីតាំងដីមួយផ្នែករបស់ស្នងការដ្ឋាននគរបាលខេត្តកំពតមានទំហំដី១៤.៤៧១ម៉ែត្រក្រឡា ដើម្បីធ្វើការផ្លាស់ប្តូរជាមួយផ្លូវរបស់ភាគីឯកជន។

**មាត្រា ២.-**

ការកត់ត្រាផ្លូវទ្រព្យសម្បត្តិថ្មី ចូលក្នុងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្តដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ សាលាខេត្តព្រៃវែង សាលាខេត្តកំពង់ស្ពឺ សាលាខេត្តកំពត និង មន្ទីរជំនាញពាក់ព័ន្ធ ស្របតាមគោលការណ៍រាជរដ្ឋាភិបាល។

**មាត្រា ៣.-**

ការបំពេញបែបបទធ្វើកម្មសិទ្ធិរបស់ភាគីឯកជននៅលើទីតាំងរបស់រដ្ឋត្រូវប្រព្រឹត្តទៅតាមច្បាប់ និង គោលការណ៍កំណត់ជាធរមាន។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និង អភិបាលគ្រប់ខេត្តពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ.ថ្ងៃទី [illegible] ៨ ឆ្នាំ២០០៧

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋាន រដ្ឋសភា
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-អគ្គលេខាធិការ រាជរដ្ឋាភិបាល
-ដូចមាត្រា ៥
-ឯកសារ-កាលប្បវត្តិ